THE UNIVERSITY OF CHICAGO MEDICINE | Center for Asian Health Equity

ថ្ងៃទី ៣០ ខែមីនាឆ្នាំ ២០២០

## ចូលកុំបណ្តោយឱ្យមានការមាក់ងាយ ការរើសអើង នឹងភាពភ័យខ្លាចចំពោះការប្រាស្រ័យទាក់ទងនឹងប្រជាជន ដែលមានដើមកំណើតអាស៊ី នៅពេលកំពុងមានការឆ្លងរាតត្បាត ដោយមេរោគ កូវីដ ១៩ (COVID-19)

យោងតាមមជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺ (CDC) សហរដ្ឋអាមេរិកបានបញ្ជាក់ថា នៅពេលនេះសហរដ្ឋអាមេរិកមានករណីឆ្លង ដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់បំផុតនៅទូទាំងពិភពលោកពោល គឺមានចំនួនជាង ១២២.៦៥៣ នាក់ និងច្រើនជាង ២.១១២ នាក់បានស្លាប់។ នៅពេលចំនួនអ្នកឆ្លង នៅតែបន្តកើនឡើងនោះ របាយការណ៍អំពីបញ្ហានៃការស្អប់ខ្ពើមជនបរទេសដែលទាក់ទងនឹងជំងឺឆ្លង ជាតិសាសន៍និយម ការរើសអើង ការយាយី និងអំពើហឹង្សាលើរាងកាយចំពោះប្រជាជនអាស៊ីបានកើនឡើង។ មជ្ឈមណ្ឌលសមធម៌សុខាភិបាលអាស៊ីនៃសាកលវិទ្យាល័យឱសថសាស្ត្រ ឈីកាហ្គោ និងជាដៃគូសហគមន៍របស់យើង - សម្ព័ន្ធការងារសុខភាពអាស៊ី ដែលជាអ្នកតស៊ូមតិដើម្បីសមភាពមនុស្សជាតិ បានថ្កោលទោសរាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ការរើសអើង និងអំពើហិង្សា។

នេះមិនមែនជាលើកទីមួយទេក្នុងប្រវត្តិសាស្ត្រ ដែលក្រុមជនជាតិជាក់លាក់មួយ ត្រូវទទួលរងការរើសអើង ដោយសារមានការភ័យខ្លាចនៃការរីករាលដាលជំងឺ ដែលបណ្តាលមកពីការផ្ទុះជំងឺឆ្លងនេះ។ ជនអន្តោប្រវេសន៍ជនជាតិជ្វីហ្វរុស្ស៊ី ដែលរស់នៅទីក្រុងញូវយ៉ក ត្រូវបានទទួលរងនូវការរើសអើង ក្នុងកំឡុងពេលផ្ទុះជំងឺអាសន្នរោគក្នុងឆ្នាំ ១៨៩២ ។ នៅពេលដែលការផ្ទុះឡើងនៃជំងឺអេបូឡាកើតឡើងក្នុងឆ្នាំ ២០១៣ ជនជាតិអាហ្វ្រិកបានរងទុក្ខយ៉ាងខ្លាំង។

ខណៈពេលដែលប្រទេសនេះ កំពុងបន្តកំណត់អត្តសញ្ញាណនិងអនុវត្តយុទ្ធសាស្ត្រ សម្រាប់ការទប់ស្កាត់ជំងឺការភ័យខ្លាច ដែលជាប់ទាក់ទងនឹងការមាក់ងាយ ការរើសអើង នឹងរារាំងដល់កិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាសុខភាពសាធារណៈរបស់យើង ជាជំងឺ កូវីដ១៩ (COVID-19) ។ លើសពីនេះទៀត បុគ្គលគ្រប់រូប ក្រុមគ្រួសារ និង សហគមន៍នានា បានយល់ដឹងរួចមកហើយ នូវផលប៉ះពាល់នៃជំងឺរាតត្បាតរ៉ាំរ៉ៃ ជំងឺកូវីដ ១៩ (COVID-19) នៅទូទាំងសហរដ្ឋអាមេរិកនិងនៅជុំវិញពិភពលោក។ ឥឡូវនេះច្រើនជាងពេលណាៗទាំងអស់ យើងត្រូវក្រោកឈរនិងធ្វើការរួមគ្នា ដើម្បីបន្ថយល្បឿនការរីករាលដាល និងបញ្ឈប់ការចម្លង ជំងឺ កូវីដ ១៩ (COVID-19) ជាជាងការឃោសនា អោយមានភាពភ័យខ្លាចនៃគ្រប់ទំរង់ទាំងអស់។

នេះជាការពិត ដូចដែលយើងដឹងៈ

- ការផ្ទុះរាតត្បាតនៃមេរោគឆ្លងថ្មី ឈ្មោះ វីរុសកូរ៉ូណា ណូវែល ដែលក្រោយមក ត្រូវបានគេដាក់ឈ្មោះ ថា កូវីដ ១៩ (COVID-19) ត្រូវបានគេរកឃើញដំបូង នៅក្នុងទីក្រុងវូហាន ប្រទេសចិន កាលពី ខែធ្នូឆ្នាំ ២០១៩ ។
- កូវីដ ១៩(COVID-19) ត្រូវបានប្រកាសដោយអង្គការសុខភាពពិភពលោកនៅថ្ងៃទី ១១ ខែមីនាឆ្នាំ ២០២០ ។
- នៅថ្ងៃទី ២៩ ខែមីនាឆ្នាំ ២០២០ ជំងឺ កូវីដ ១៩ (COVID-19) បានរីករាលដាល ដល់ប្រទេសក្នុងតំបន់ ជាង ២០០ ប្រទេស ហើយដែលមានករណីឆ្លងចំនួនជាង ៧០០.០០០ ករណីនិងមានអ្នកស្លាប់ជាង ៣០.០០០ នាក់។
- មនុស្សគ្រប់រូបរួមគ្នា ជួយបញ្ឈប់ការមាក់ងាយនឹងរើសអើងប្រជាជន ដែលទាក់ទងទៅនឹងជំងឺកូវីដ ១៩ នេះបាន ដោយត្រូវដឹងអំពី ការពិតនិងចែករំលែកវាជាមួយអ្នកដទៃទៀត នៅក្នុងសហគមន៍របស់អ្នក។

កូរ៉ូណា វីរុស មិនបានរើសអើង ដោយផ្អែកលើពូជសាសន៍និងជាតិពន្ធនោះទេ តែការភ័យខ្លាចទៅវិញទេ ដែលបានបង្កបញ្ហានេះឡើង។ យើងមិនត្រូវបណ្តោយឱ្យការភ័យខ្លាច ការមាក់ងាយ និងការរើសអើង មានប្រៀបលើសាមគ្គីភាពរបស់យើង ដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលលើពិភពលោកនៃជំងឺប្រភេទថ្មី ដែលបង្កឡើងដោយមេរោគ កូវីដ ១៩ (COVID-19) នេះជាដាច់ខាត ។

ស្វែងរកព័ត៌មានបន្ថែមៈ **មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ-CDC** , **អង្គការសុខភាពពិភពលោក-WHO**